វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- កម្មវិធីគោលនយោបាយរូបិយវត្ថុថ្មីរបស់កម្ពុជាគឺជាមូលហេតុដែលធ្វើឱ្យការទិញប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ
- គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ថៃបោះឆ្នោតអោយមានការរក្សាស្ថិរភាពអត្រាការប្រាក់
- វិស័យសេវាកម្មរបស់អាមេរិកធ្លាក់ចុះខែទីពីរបន្តបន្ទាប់គ្នាដោយសារការបិទរដ្ឋាភិបាល

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### កម្មវិធីគោលនយោបាយរូបិយវត្ថុថ្មីរបស់កម្ពុជាគឺជាមូលហេតុដែលធ្វើឱ្យការទិញប្រាក់ដុល្លារអាមេរិកធ្លាក់ចុះ

ដើម្បីសម្រេចបាននូវគោលដៅអត្រាប្តូរប្រាក់របស់ខ្លួន ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារចំនួន ៨៧៥លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៨ ពោលគឺធ្លាក់ចុះ ៩% ធៀបនឹងឆ្នាំ២០១៧។

មូលហេតុដែលមានការទិញប្រាក់ដុល្លារតិចជាងមុន ត្រូវបានគេជឿថាបណ្តាលមកពីគោលនយោបាយរូបិយវត្ថុថ្មីរបស់ធនាគារជាតិនៃកម្ពុជា ដែលហៅថា ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(LPCO)។ សម្រាប់ LPCO ធនាគារជាតិនៃកម្ពុជាបានធ្វើការជាមួយធនាគារពាណិជ្ជ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា ដើម្បីបង្កើនសន្ទនីយភាព(liquidity)ប្រាក់រៀល ដើម្បីលើកទឹកចិត្តការប្រើប្រាស់ប្រាក់រៀល។

របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារជាតិនៃកម្ពុជា បានបង្ហាញថា អត្រាប្តូរប្រាក់ធៀបនឹងប្រាក់ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ ត្រូវបានរក្សាលំនឹងដោយជោគជ័យ ពោលគឺស្មើនឹង ៤ ០៥០រៀលក្នុងមួយដុល្លារអាមរិក។

### តារាងប្រចាំសប្តាហ៍៖ ពាណិជ្ជកម្មអន្តរជាតិរបស់បណ្តាប្រទេសសមាជិកអាស៊ាន

តារាងនៅក្នុងសប្តាហ៍នេះ បង្ហាញអំពីសារៈសំខាន់នៃពាណិជ្ជកម្មអន្តរជាតិរបស់បណ្តាប្រទេសសមាជិកអាស៊ាននៅក្នុងឆ្នាំ២០១៧ គិតជាភាគរយនៃ ផសស។ ប្រទេសសិង្ហបុរីមានលក្ខណៈពិសេសក្នុងពាណិជ្ជកម្មអន្តរជាតិ ដែលផលបូកសរុបនៃការនាំចេញ នាំចូលមានទំហំជាង ៣០០%នៃផសស (ផលបូកនេះអាចខ្ពស់ជាង ផសស ពីព្រោះការគណនា ផសស គឺបញ្ចូលតែលទ្ធផលដែលការនាំចេញដកការនាំចូល)។ ការនាំចេញ និងការនាំចូលរបស់ប្រទេសវៀតណាមក៏មានសារៈសំខាន់ខ្លាំងចំពោះសកម្មភាពសេដ្ឋកិច្ចរបស់ខ្លួនផងដែរ ដែលរួមមាន ២០០%នៃផ.ស.ស។

សកម្មភាពសេដ្ឋកិច្ចរបស់ប្រទេសមីយ៉ាន់ម៉ា និងឥណ្ឌូនេស៊ី ពឹងផ្អែកតិចតួចណាស់លើពាណិជ្ជកម្ម ដោយក្នុងនោះការនាំចេញ និងនាំចូលមានទំហំតិចជាង ៥០% នៃ ផសស។

ការនាំចេញ និងការនាំចូលរបស់ប្រទេសកម្ពុជាធៀបនឹងបណ្ដាប្រទេសសមាជិកអាស៊ានទាំងអស់ គឺនៅប្រហាក់ប្រហែលចំនុចកណ្ដាល គឺប្រមាណជា ៨៥%នៃ ផសស។

**ពាណិជ្ជកម្មអន្តរជាតិឆ្នាំ២០១៧ គិតជាភាគរយនៃ ផសស (%)**




ប្រភព៖ ធនាគារពិភពលោក

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ថៃ បោះឆ្នោតអោយមានការរក្សាស្ថិរភាពអត្រាការប្រាក់

កាលពីសប្ដាហ៍មុន គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ប្រទេសថៃបានបោះឆ្នោតក្រោមសម្លេងបួនទល់នឹងពីរនាក់ ដើម្បីរក្សាគោលនយោបាយអត្រាការប្រាក់របស់ធនាគារកណ្ដាលរបស់ខ្លួន នៅត្រឹមកម្រិត១,៧៥% (សេចក្ដីប្រកាសជាលាយល័ក្ខអក្សរជាPDF) ដោយអវត្តមានសមាជិកម្នាក់ ។

នៅក្នុងកិច្ចពិភាក្សានោះ សមាជិកបួននាក់ដែលបានបោះឆ្នោតរក្សាកម្រិតអត្រាការប្រាក់នោះ បានលើកឡើងថា សេដ្ឋកិច្ចថៃនៅតែអាចបន្តស្រូបលទ្ធភាពពីតម្រូវការក្នុងស្រុក ទោះបីជាតម្រូវការក្រៅស្រុកមានការថយចុះក៏ដោយ ហើយអតិផរណារួម (Headline inflation) មិនមានការកើនឡើងដោយសារតែការថយចុះតម្លៃថាមពល ឯអតិផរណាស្នូល (Core inflation) ថិតនៅក្នុងកម្រិតស្របនឹងការព្យាករណ៍។

សម្រាប់សមាជិកពីរនាក់ដែលបានបោះឆ្នោតបង្កើនអត្រាការប្រាក់ ០,២៥ ពិន្ទុភាគរយនៃគោលនយោបាយអត្រាការប្រាក់ បានផ្ដល់ហេតុផលថា សេដ្ឋកិច្ចថៃកំពុងរីកចម្រើនហួសពីសក្ដានុពលរបស់ខ្លួន ហើយស្ថានភាពហិរញ្ញវត្ថុ នឹងអាចនៅរក្សាលំនឹងបាន ទោះបីជាមានការតម្លើងអត្រាការប្រាក់ក៏ដោយ។

នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ ធនាគារកណ្ដាលបានតម្លើងអត្រាការប្រាក់នៅក្នុងគោលនយោបាយរបស់ខ្លួនជាលើកដំបូងក្នុងរយៈពេលប្រាំពីរឆ្នាំកន្លងមកនេះ។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### វិស័យសេវាកម្មរបស់អាមេរិកធ្លាក់ចុះខែទីពីរបន្តបន្ទាប់គ្នាដោយសារការបិទរដ្ឋាភិបាល

យោងតាមការអង្កេតចុងក្រោយរបស់ប្រតិបត្តិទិញ និងផ្គត់ផ្គង់នៃវិទ្យាស្ថានសម្រាប់គ្រប់គ្រងការផ្គត់ផ្គង់(ISM) នៅសប្ដាហ៍មុនបានអោយដឹងថា ការព្រួយបារម្ភអំពីការបិទផ្នែកខ្លះនៃរដ្ឋាភិបាលសហព័ន្ធអាមេរិក បាននាំឱ្យមានការធ្លាក់ចុះសកម្មភាពសេដ្ឋកិច្ចនៅក្នុងវិស័យមិនមែនផលិតកម្ម ។

សន្ទស្សន៍របស់សកម្មភាពមិនមែនផលិតកម្មដែលចេញដោយ ISM បានធ្លាក់ចុះ ១,៣ពិន្ទុនៅក្នុងខែមករា មកត្រឹម៥៦,៧ ដែលជាតួលេខទាបបំផុត គិតចាប់តាំងពីខែកក្កដាឆ្នាំ២០១៨មក។ ប៉ុន្តែ ទោះបីជាមានការធ្លាក់ចុះនៃសន្ទស្សន៍នេះក៏ដោយ ក៏លទ្ធផលនេះនៅតែស្របទៅនឹងសេដ្ឋកិច្ចដែលនៅតែបន្តរីកចម្រើន (លទ្ធផលសន្ទស្សន៍ដែលខ្ពស់ជាង៥០ បង្ហាញពីការកើនឡើងក្នុងវិស័យសេវាកម្ម ដែលមានចំនួនច្រើនជាងពីរភាគបីនៃសកម្មភាពសេដ្ឋកិច្ចរបស់អាមេរិក)។

អ្នកឆ្លើយសំណួរស្ទង់មតិក៏បានសម្ដែងការខកចិត្ត និងការព្រួយបារម្ភផងដែរ ចំពោះការចំណាយខ្ពស់ដែលពួកគេកំពុងប្រឈម

បន្ទាប់ពីមានការដាក់ពន្ធគយមួយចំនួន ប៉ុន្តែជាទូទៅពួកគេនៅតែមានសុទិដ្ឋិនិយមចំពោះអនាគតផ្នែកអាជីវកម្ម។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះរួមមាន៖ ផសស របស់ប្រទេសជប៉ុន និងម៉ាឡេស៊ី ក្នុងត្រីមាសទី៤ ព្រមទាំងទិន្នន័យតុល្យភាពពាណិជ្ជកម្មរបស់បណ្តាប្រទេសភាគច្រើននៅក្នុងតំបន់អាស៊ាន។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃច័ន្ទ ទី១១ ខែកុម្ភៈ

- អតិផរណារបស់ប្រទេសប្រ៊ុយណេ សម្រាប់ខែធ្នូ
- ឧស្សាហកម្មផលិតកម្មរបស់ម៉ាឡេស៊ី សម្រាប់ខែធ្នូ
- និកម្មភាពរបស់ម៉ាឡេស៊ី សម្រាប់ខែធ្នូ
- ទុនបម្រុងរូបិយប័ណ្ណបរទេស របស់ចិន ខែមករា
- ការវិនិយោគផ្ទាល់ពីបរទេសរបស់ហ្វីលីពីន សម្រាប់ខែវិច្ឆិកា
- ការលក់រាយរបស់ឥណ្ឌូនេស៊ី សម្រាប់ខែធ្នូ

ថ្ងៃអង្គារ ទី១២ ខែកុម្ភៈ

- ការវិនិយោគផ្ទាល់ពីបរទេស របស់ចិន សម្រាប់ខែមករា
- តុល្យភាពពាណិជ្ជកម្មរបស់ហ្វីលីពីន សម្រាប់ខែធ្នូ
- ការលក់រាយរបស់សិង្ហបុរី សម្រាប់ខែធ្នូ
- តម្លៃអចលនទ្រព្យរបស់ឥណ្ឌូនេស៊ី សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- ការបញ្ជាទិញឧបករណ៍គ្រឿងម៉ាស៊ីនរបស់ជប៉ុន សម្រាប់ខែមករា

ថ្ងៃពុធ ទី១៣ ខែកុម្ភៈ

- ភាពគ្មានការងារធ្វើនៅកូរ៉េខាងត្បូង សម្រាប់ខែមករា
- តុល្យភាពពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី ខែមករា
- ការលក់រាយរបស់ម៉ាឡេស៊ី សម្រាប់ខែធ្នូ
- អតិផរណារបស់អាមេរិក សម្រាប់ខែមករា

ថ្ងៃព្រហស្បតិ៍ ទី១៤ ខែកុម្ភៈ

- របាយការណ៍ថវិកាប្រចាំខែរបស់ អាមេរិក សម្រាប់ខែមករា
- ការប៉ាន់ស្មានបឋមទៅលើផសសរបស់ជប៉ុនសម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- និកម្មភាពរបស់ប្រទេសបារាំង សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- ផសស របស់ម៉ាឡេស៊ី សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨

ថ្ងៃសុក្រ ទី១៥ ខែកុម្ភៈ

- គណនីចរន្តរបស់កូរ៉េខាងត្បូង សម្រាប់ខែធ្នូ
- ការវិនិយោគមូលបត្របំណុលបរទេសរបស់ជប៉ុន សម្រាប់ ០៩ ខែកុម្ភៈ
- អតិផរណារបស់ចិន សម្រាប់ខែមករា
- ផលិតកម្មឧស្សាហកម្ម របស់ជប៉ុន សម្រាប់ខែធ្នូ
- តុល្យភាពពាណិជ្ជកម្មរបស់ប្រ៊ុយណេ សម្រាប់ខែវិច្ឆិកា